ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Jan-2015, 15:49
CMS/CFO: Sann Rada

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម, ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៥**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស/បារាំង**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

---

# សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីជនជាប់ចោទ នួន ជា**
សុន អរុណ
Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែមករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក")៖

**បានទទួល**បណ្តឹងសាទុក្ខ[1]ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១[2], **បានទទួល**សំណើសហព្រះរាជអាជ្ញាដែលដាក់នៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១៥ សុំអង្គជំនុំជម្រះតុលាការកំពូល បង្គាប់សហមេធាវីការពារក្តី ខៀវ សំផន ("មេធាវីការពារក្តី") កែតម្រូវវិការៈដែលរងចោទប្រកាន់នៃសារណាបណ្តឹងសាទុក្ខ("សំណើសុំ")[3],

**កត់សម្គាល់**ថា សហព្រះរាជអាជ្ញា ដែលបានកត់សម្គាល់ឃើញថា "មានកថាខណ្ឌប្អូន ត្រូវបានបន្ថែម លើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលត្រូវបានធ្វើការកែតម្រូវ"[4] បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល"ទទួលយក"សារណាដែលបានកែតម្រូវនេះ ហេតុដូច្នេះ ដើម្បី"បញ្ចប់នូវភាពមន្ទិលសង្ស័យណាមួយដែលនាំឲ្យភាគីយល់ច្រឡំថា ខ្លួនគួរត្រូវឆ្លើយតបនឹងបណ្តឹងសាទុក្ខនេះ"[5],

**កត់សម្គាល់**ថា សហព្រះរាជអាជ្ញាលើកឡើងថា សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន បើទោះជាបានកែតម្រូវក៏ដោយ គឺមានកំហុស ដោយហេតុថា សារណានេះពុំបានបញ្ជាក់ឲ្យបានច្បាស់លាស់"ថាតើការអំណះអំណាងណាខ្លះ ត្រូវបានធ្វើឡើង ដើម្បីគាំទ្រទៅនឹងទទ្ធីករណ៍នៃបណ្តឹងសាទុក្ខណាមួយឡើយ

[1] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុសំណុំរឿង ០០២/០១ ឯកសារលេខ F11, ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៤។ បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ F16, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៤។ *[Corrigé 1] Mémoire d'appel de la Défense de M. KHIEU Samphân contre le jugement rendu dans le procès 002/01*, ឯកសារលេខ F17, ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ ("សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន")។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ E313/3/1, ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០១៤។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាក្រមក្នុងសំណុំរឿង ០០២/០១, ឯកសារលេខ E313/1/1, ចុះថ្ងៃទី ២៩ ខែ កញ្ញា ២០១៤; សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើ សំណុំរឿង ០០២/០១, ឯកសារលេខ E313/2/1, ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៤ ("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ")។

[2] សាលក្រមនៃសំណុំរឿងលេខ ០០២/០១ ឯកសារលេខ E313, ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៤។

[3] សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំដោះស្រាយលើវិការៈនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ឯកសារលេខ F18។

[4] សំណើសុំ កថាខណ្ឌ ២។

[5] សំណើសុំ ទំព័រ ៣។

ហើយប្រសិនបើមាន ថាតើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខណាមួយ ត្រូវបានបោះបង់ចោល"[6] និងកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គជំនុំជម្រះ បង្គាប់មេធាវីការពារក្តី ដាក់ឯកសារបន្ថែម ដោយបង្ហាញ "ថាតើ កថាខណ្ឌនៃសារណាបណ្តឹងសាទុក្ខមួយណា ជាប់ពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខណាខ្លះ ដែលមាននៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនោះ"[7],

**កត់សម្គាល់**ថា សារណាតបរបស់ ខៀវ សំផន ដែលក្នុងនោះមេធាវីការពារក្តី បានធ្វើការអង្កេតជាលើកដំបូងឃើញថា សារណាដែលបានធ្វើការកែតម្រូវរបស់ខ្លួន ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលទទួលយករួចរាល់ហើយ ហេតុដូចនេះ ពុំចាំបាច់មានការបំភ្លឺបន្ថែមទៀតទាក់ទងនឹងបញ្ហានេះទេ[8]។ ចំពោះចំណុចទីពីរមេធាវីការពារក្តីបានអះអាងថា ទោះបីជាមានការផ្លាស់ប្តូរ និងបញ្ចូលគ្នាក៏ដោយ ក៏អំណះអំណាងនៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន នៅតែមានទំនាក់ទំនងច្បាស់លាស់ជាមួយនឹងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ ដែលបានលើកឡើងក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[9], ហើយបានអះអាងថាសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ពុំបានរំលោភបំពានលើបទបញ្ញត្តិជាធរមានណាមួយឡើយ។ មេធាវីការពារក្តីលើកឡើងថា សារណាបណ្តឹងសាទុក្ខនោះ ពុំមានវិការៈឡើយ ហើយសំណើនេះ គប្បីត្រូវបានបដិសេធចោល[10]។

**កត់សម្គាល់**ថា ឧបសម្ព័ន្ធ[11]ដែលបានដាក់ដោយមេធាវីការពារក្តី មានភ្ជាប់នូវគំនិតមួយក្នុង"ការជួយដល់សហព្រះរាជអាជ្ញា [...] ដោយបានផ្តល់នូវការបញ្ជាក់មួយចំនួនលើការផ្លាស់ប្តូរខ្លះ និងការបញ្ចូលគ្នានៃកំហុសរវាងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ"[12],

---

[6] សំណើសុំកថាខណ្ឌ ៥។

[7] សំណើសុំទំព័រ ៣។

[8] សារណាតបរបស់មេធាវីការពារក្តីរបស់ ខៀវ សំផន ទៅនឹង«សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យដោះស្រាយចំពោះវិការៈនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន», ឯកសារលេខ F18/1, ថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៥ ("សារណាតប "), កថាខណ្ឌ ៦។

[9] សារណាតប កថាខណ្ឌ ៩ និង ១០។

[10] សារណាតប កថាខណ្ឌ ៧, ៩ និង ១២។

[11] *Déplacements et fusions intervenus entre la déclaration d'appel et le mémoire d'appel*, ឯកសារលេខ F18/1.2, ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០២៥ ("ឧបសម្ព័ន្ធ ")។

[12] សារណាតប កថាខណ្ឌ ១១ (ការបកប្រែមិនផ្លូវការ)។

**កត់សម្គាល់**ថា ចម្លើយតបរបស់សហព្រះរាជអាជ្ញា[13] ដែលក្នុងនោះ បានអះអាងថា សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ពុំបានបញ្ជាក់ច្បាស់លាស់នូវទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ ពុំបានបញ្ជាក់នូវមាតិកាជាក់លាក់ និងពុំបានរៀបរាប់ពីលក្ខណៈនៃកំហុសដែលបានចោទប្រកាន់នោះ ដែលបណ្តាលឱ្យភាគី និងអង្គជំនុំជម្រះ ដោះស្រាយលើសារណាដែលពុំមានលក្ខណៈច្បាស់លាស់[14]។

**រំលឹក**ថា មាត្រា ១០.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ យោងតាមមាត្រានេះ "ក្រឡាបញ្ជីដែលពាក់ព័ន្ធ" ត្រូវទទួលខុសត្រូវក្នុងការពិនិត្យផ្ទៀងផ្ទាត់ អំពីទំរង់បែបបទនៃឯកសារដែលបានដាក់ ឱ្យស្របទៅតាមបទបញ្ញត្តិទាក់ទងនឹងការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, ក៏ដូចជាមាត្រា ៣.១៧ នៃសេចក្តីណែនាំអនុវត្ត ដែលចែងយ៉ាងពិសេសថា "ការកែតម្រូវឯកសារដើម ត្រូវមានការព្រមព្រៀងពីក្រឡាបញ្ជី"[15],

**ដោយពិចារណាឃើញ**ថា បញ្ហាថាតើសំណៅឯកសារដែលបានធ្វើការកែតម្រូវនេះ គប្បីត្រូវបានទទួលយក ឬយ៉ាងណានោះ ពុំបានបើកចំហសម្រាប់ការធ្វើការពិភាក្សាដេញដោលនោះទេ ប៉ុន្តែ បញ្ហានេះ ត្រូវបានដោះស្រាយយ៉ាងដាច់ដោយឡែកដោយក្រឡាបញ្ជីពាក់ព័ន្ធ, និងថា សហព្រះរាជអាជ្ញា ក៏ដូចជាភាគីដទៃទៀតដែរ ពុំតម្រូវឱ្យធ្វើការ "ជំទាស់" ឬ "ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយក" នូវឯកសារណាមួយដែលបានដាក់នៅចំពោះមុខឡើយ,

**ដោយពិចារណាឃើញ**ថា នៅពេលដែលក្រឡាបញ្ជី ទទួលយកសំណៅនៃឯកសារដែលបានធ្វើការកែតម្រូវរួចហើយ ពុំតម្រូវឱ្យមានការបំភ្លឺណាមួយទាក់ទងនឹងបញ្ហា ថាតើ សំណៅនៃសារណាបណ្តឹងសាទុក្ខ

---

[13] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាតបរបស់មេធាវីការពារលើសំណើសុំដោះស្រាយវិការៈនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ឯកសារលេខ F18/2, ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៥ ("ចម្លើយតប")។ ការអនុញ្ញាតសុំដាក់ឯកសារនេះជាភាសាអង់គ្លេសតែប៉ុណ្ណោះ ដែលភាសាខ្មែរ ដាក់តាមក្រោយឱ្យបានឆាប់រហ័សបំផុត ត្រូវបានអនុញ្ញាតដោយអនុលោមតាម មាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១២ ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")។

[14] ចម្លើយតប កថាខណ្ឌ ៤, ៥, ៧ និង ៩ ដល់ ១១។

[15] *សូមមើលផងដែរ* សន្ទានុក្រមនៃវិធានផ្ទៃក្នុង (វិ.លើកទី ៨), "ក្រឡាបញ្ជី" (ចែងថា ក្រឡាបញ្ជី "ជាអ្នកទទួលខុសត្រូវជាពិសេស ក្នុងការរក្សាទុកនូវរាល់ឯកសារផ្លូវការនៃការជំនុំជម្រះទទួលយកនូវឯកសារច្បាប់ដើមពីភាគីទាំងអស់ និងធានាដល់ការជូនដំណឹងរាល់សេចក្តីសម្រេច")។

របស់ខៀវ សំផន មួយណា ដែលភាគី គប្បីត្រូវយកមកធ្វើការពិចារណានោះឡើយ បើទោះជា ឯកសារនោះ ជំនួសភ្លាមៗនូវឯកសារពីមុនក៏ដោយ,

**ដោយពិចារណាឃើញ**ថា ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកថា ជាការពុំសមស្រប ក្នុងការអនុវត្តនូវមាត្រា ៣.១៧ *ស្ទួន* នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ,

**រំលឹក**ថា វិធាន ១០៥(៣)នៃវិធានផ្ទៃក្នុង[16] ចែងថា សារណាបណ្ដឹងសាទុក្ខ ត្រូវ"បញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ" ដូចមានបញ្ជាក់នៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខឱ្យបានច្បាស់លាស់តាមដែលអាចធ្វើទៅបាន និងថា ទាក់ទងនឹងទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខនីមួយៗ ភាគីតម្រូវឱ្យបញ្ជាក់ពីកំហុសអង្គច្បាប់ ឬអង្គហេតុ និងកំហុសដែលនាំឱ្យសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមោឃៈ ឬនាំឱ្យមានភាពមិនយុត្តិធម៌[17],

**ដោយពិចារណាឃើញ**ថា ទំនាក់ទំនងយ៉ាងជាក់ច្បាស់ រវាងទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ ដែលបានបញ្ជាក់ក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសំអាងហេតុគាំទ្រនីមួយៗ នៅក្នុងសារណាបណ្ដឹងសាទុក្ខ ពុំបានចែងនៅក្នុងវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យភាគី ធ្វើការលើកឡើងអំពីទំនាក់ទំនងនេះ ដែលកំណត់ថា ប្រសិនបើ អំណះអំណាងណាមួយនៅក្នុងសារណាបណ្ដឹងសាទុក្ខ ពុំមានទាក់ទងទៅនឹងទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខនៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខនោះទេ អំណះអំណាងនោះ ពុំត្រូវបានយកមកធ្វើការពិចារណាដូចធម្មតាឡើយ ដរាបណា អំណះអំណាងនោះ មានផលប្រយោជន៍នៃយុត្តិធម៌ ហើយថា ប្រសិនបើទឡ្ហីករណ៍ណាមួយនៃបណ្ដឹងសាទុក្ខ ពុំមានសំអាងហេតុគាំទ្របន្ថែមទេនោះ ទឡ្ហីករណ៍នេះ ពុំត្រូវបានយកមកពិចារណាឡើយ,

**ដោយសង្កេតឃើញ**ថា មេធាវីការពារក្ដី នៅក្នុងឧបសម្ព័ន្ធរបស់ខ្លួន ពុំបានភ្ជាប់នូវទំនាក់ទំនងរវាងកថាខណ្ឌមួយចំនួនយ៉ាងច្បាស់ក្រឡែកនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ជាមួយទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខនៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ប៉ុន្តែអំណះអំណាងមួយចំនួន ទំនងជាទំនាក់ទំនងជាមួយនឹងទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ ហើយមានលក្ខណៈត្រឹមត្រូវ[18]។

---

[16] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១១ ("វិធានផ្ទៃក្នុង")។

[17] *សូមមើលផងដែរ* វិធាន ១០៥(២)(ក) នៃវិធានផ្ទៃក្នុង និង(ខ)។

[18] *សូមមើលឧ.* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៥៩ ដល់ ១៦៤ (ដែលពុំត្រូវបានបញ្ចូលនៅក្នុងតារាងនៃឧបសម្ព័ន្ធ ប៉ុន្តែមានការទំនាក់ទំនងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៧)។ សារណាបណ្ដឹង

**អាស្រ័យហេតុនេះ÷**

**សម្រេចបដិសេធ**សំណើនេះចោលជាអសារបង់។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

---

សាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣២ (ពុំត្រូវបានបញ្ចូលនៅក្នុងតារាងឧបសម្ព័ន្ធ ប៉ុន្តែជាប់ទាក់ទងទៅនឹងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ កថាខណ្ឌ ៨០)។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៨៣ ដល់ ៣៨៧ (ដែលពុំបញ្ចូលនៅក្នុងតារាងនៃឧបសម្ព័ន្ធ ប៉ុន្តែមានទំនាក់ទំនងទៅនឹងសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០២)។